**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការរៀនតាមប្រព័ន្ធអេឡិចត្រូនិក (E-Learning) សម្រាប់ជំនួយដល់សិស្សានុសិស្ស

ដើម្បីជាជំនួយដល់ការសិក្សារបស់សិស្សានុសិស្សថ្នាក់ទី៩ និងថ្នាក់ទី១២ ដែលបានផ្អាកការសិក្សាជាបណ្តោះអាសន្ននៅគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនក្នុងក្រុងសៀមរាប ខេត្តសៀមរាប ក្នុងការចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺ Covid-19 ក៏ដូចជាសម្រាប់សិស្សានុសិស្សដទៃទៀតដែលមានបំណងទទួលការបំប៉នបន្ថែម ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតកម្មវិធីសិក្សា "ការរៀនតាមប្រព័ន្ធអេឡិចត្រូនិក" (E-Learning) ដោយឥតគិតថ្លៃលើមុខវិជ្ជាឯកទេសចំនួន០៦ ដែលអាចឱ្យប្អូនៗសិស្សានុសិស្សទាំងអស់អាចសិក្សាដោយខ្លួនឯងបាននៅលើបណ្តាញទំនាក់ទំនងសង្គមផ្លូវការ និងប្រព័ន្ធសិក្សាតាមអេឡិចត្រូនិករបស់ក្រសួង។ កម្មវិធីនេះបង្កើតឡើងក្នុងគោលបំណងជំនួយដល់ការសិក្សារបស់ប្អូនៗសិស្សានុសិស្សអាចនៅតែបន្តការសិក្សាបានដោយខ្លួនឯង នៅគ្រប់ទីកន្លែងនិងស្របតាមពេលវេលាផ្ទាល់ខ្លួនរបស់សិស្សានុសិស្ស សម្រាប់ជាជំនួយស្មារតីក្នុងការត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ តាមកាលបរិច្ឆេទដែលបានគ្រោងទុក។ មុខវិជ្ជាឯកទេសបង្រៀនទាំង០៦ រួមមាន៖ គណិតវិទ្យា ប្រវត្តិវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងភាសាខ្មែរ។

ក្រសួងនឹងដាក់ឱ្យដំណើរការកម្មវិធីបង្រៀនតាមអេឡិចត្រូនិកនេះ ចាប់ពីថ្ងៃទី**១៣ ខែមីនា ឆ្នាំ២០២០** តទៅ ដោយសិស្សានុសិស្សអាចសិក្សាបានតាមរយៈមធ្យោបាយដូចខាងក្រោម៖

១-បណ្តាញ YouTube ផ្លូវការរបស់ក្រសួង៖ **www.youtube.com/moeys** ដែលនឹងមានវីដេអូ បង្រៀនទាំងអស់ សម្រាប់សិស្សានុសិស្សអាចសិក្សាបានទៅតាមពេលវេលាជាក់ស្តែងរបស់ខ្លួន

២-ទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង៖ **www.facebook.com/moeys.gov.kh** ដែលនឹងធ្វើការផ្សព្វផ្សាយជារៀងរាល់ថ្ងៃ ដោយពេលព្រឹកសម្រាប់ថ្នាក់ទី៩ និងពេលរសៀលសម្រាប់ថ្នាក់ទី១២

៣-មជ្ឈមណ្ឌលសិក្សាអេឡិចត្រូនិករបស់ក្រសួង៖ **elearning.moeys.gov.kh** ដោយសិស្សានុសិស្សអាចចូលទៅសិក្សាបានដោយចូលទៅជ្រើសរើសវគ្គសិក្សា ឬមេរៀនដែលត្រូវសិក្សាដោយឥតគិតថ្លៃ និងមិនចាំបាច់ចុះឈ្មោះ (ចូលជាភ្ញៀវ)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកគ្រូ អ្នកគ្រូ មាតាបិតា អ្នកអាណាព្យាបាលសិស្សចូលរួមជំរុញលើកទឹកចិត្តប្អូនៗសិស្សានុសិស្សទាំងអស់ ជាពិសេសផ្តល់លក្ខខណ្ឌអំណោយផល ដើម្បីអាចបន្តសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកបានជាប្រចាំដោយចូលទៅក្នុងគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលបានផ្តល់ជូនខាងលើតាមការគួរ។

ថ្ងៃសុក្រ ៥រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២០

ក្រសួងអប់រំ យុវជន និងកីឡា
ព្រះរាជាណាចក្រកម្ពុជា